**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់ អូរយ៉ាដាវ ខេត្តរតនគិរី

~~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
~~~~~~~~~

- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋាន រុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឱ្យទៅជា អគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជា អគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីល័ក្ខខ័ណ្ឌ និង នីតិវិធីក្នុងការគ្រប់គ្រងកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត តំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់ អូរយ៉ាដាវ ខេត្តរតនគិរី ដែលមានទំហំប្រមាណ ១០១ ៣៤៨ ( មួយរយមួយពាន់ បីរយសែសិបប្រាំបី) ហិកតា ស្ថិតក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ ៖

- អភិវឌ្ឍតំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និង ទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ថែរក្សាការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងតំបន់អេកូឡូស៊ី រួមទាំងធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ ជាពិសេសប្រភេទដែលកំពុងរងគ្រោះ និងប្រភេទជិតផុតពូជ
- រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជម្រកសម្រាប់ការស្នាក់អាស្រ័យសុខសាន្តតាមរដូវកាល និងការបន្តពូជរបស់ពពួកសត្វព្រៃ
- អភិវឌ្ឍកីឡាប្រមាញ់បែបកម្សាន្តគំរូដែលមានកម្រិតកំណត់ខ្នាតអន្តរជាតិ ប្រកបដោយនិរន្តរភាព នៅក្នុង ព្រះរាជាណាចក្រកម្ពុជា
- រៀបចំជាមជ្ឈមណ្ឌលស្រាវជ្រាវស្តីពីអេកូឡូស៊ីព្រៃឈើ និងសត្វព្រៃ និងជាតំបន់ឡូត៍គំរូសម្រាប់ការសិក្សាស្រាវជ្រាវប្រភេទរុក្ខជាតិព្រៃឈើសំខាន់ៗនៃតំបន់អេកូឡូស៊ីព្រៃល្បោះ

- ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន តាមរយៈការផ្តល់ឱកាសការងារក្នុងវិស័យទេសចរណ៍ធម្មជាតិ និងធានាឱ្យមាននិរន្តរភាពអេកូឡូស៊ី សេដ្ឋកិច្ចសង្គម និងជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

**មាត្រា ៣.-**

តំបន់ព្រៃការពារ សម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់ អូរយ៉ាដាវ ខេត្តរតនគិរី មានព្រំប្រទល់ជាខ្សែព្រំ បិទជិតកំណត់ដោយបណ្តាចំណុចគោលចេញពីចំណុច A , ចំណុច B រហូតដល់ចំណុច S ដែលមាននិយាមការ : B(778316, 1469596) , C(767470,1475211) , D(757106, 1468587) , E(753702, 1472840) , F(750229, 1490459) , G(757991, 1507000) , H(773602, 1506993) , I(775116, 1500663) , J(776838, 1502626) , K(776846, 1504516) , ចំណុច L, ចំណុច M, ចំណុច N (778955, 1501483) , O(778304, 1502096) , P(776544, 1500043), Q(775568, 1498728) , R(776207, 1496011) និងចំណុច S ដូចមានផែនទីមាត្រដ្ឋាន ១/១៧០.០០០ ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៤.-**

ផ្ទៃក្រឡា និងចំណុចគោលនៃតំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់ អូរយ៉ាដាវ ខេត្តរតនគិរី អាចធ្វើការកែប្រែបានតាមការចាំបាច់ ដោយផ្អែកលើព័ត៌មានសិក្សាស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ បច្ចេកទេសជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែង។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ២
## ការគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រង តំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់ អូរយ៉ាដាវ ខេត្តរតនគិរី ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធានាការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាព សម្រាប់ផលប្រយោជន៍ជាតិ និងសិទ្ធិប្រើប្រាស់ជាប្រពៃណី ទំនៀមទំលាប់ ជំនឿសាសនា និងការរស់នៅ របស់សហគមន៍មូលដ្ឋាន។

**មាត្រា ៦.-**

នីតិវិធី និងដំណើរការនៃការរៀបចំគ្រប់គ្រងតំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់ អូរយ៉ាដាវ ខេត្តរតនគិរី ព្រមទាំងបទប្បញ្ញត្តិនានាជាអាទិ៍ ទាក់ទងនឹងរដូវកាលប្រមាញ់ ពេលវេលា ទីតាំង ចំនួន និងប្រភេទសត្វព្រៃដែលអនុញ្ញាតឱ្យបាញ់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**មាត្រា ៧.-**

មធ្យោបាយ និង ឧបករណ៍សម្រាប់កីឡាប្រមាញ់ត្រូវកំណត់ដោយប្រកាសរួមរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

**មាត្រា ៨.-**

វិធាននៃការបង់ប្រាក់សួយសារ និង ថ្លៃសេវាប្រមាញ់ផ្សេងៗ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៣

## ទោសប្បញ្ញត្តិ

**មាត្រា ៩.-**

បុគ្គលណាដែលធ្វើសកម្មភាពល្មើសច្បាប់ នៅក្នុងតំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់ អូរយ៉ាដាវ ខេត្តរតនគិរី ត្រូវផ្តន្ទាទោសស្របតាមច្បាប់ស្តីពីព្រៃឈើ និង ច្បាប់ពាក់ព័ន្ធផ្សេងៗទៀតជាធរមាន ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ អភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ៣ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- ឯកសារ-កាលប្បវត្តិ


ស្តីពីតំបន់ព្រៃការពារ សម្រាប់ឈើហែកំសាន្ត និងកីឡាប្រមាញ់ អូរយ៉ាដាវ រតនគិរី
សញ្ញាសំគាល់
ភូមិ
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ដីសម្បទាន
ព្រំប្រទល់តំបន់ការពារ
ផ្លូវ
ផ្លូវទឹក
ព្រំប្រទល់តំបន់ព្រៃការពារ សម្រាប់ឈើហែកំសាន្ត និងកីឡាប្រមាញ់
ព្រៃស្រោង ៦ ៣៨៩ ហ.ត
ព្រៃពាក់កណ្តាលស្រោង ១២ ៣៨៦ ហ.ត
ព្រៃល្បោះ ៧៣ ៤៤៧ ហ.ត
ព្រៃផ្សេងៗ ៦១៩ ហ.ត
ព្រៃឬស្សី ៣ ១៥០ ហ.ត
ព្រៃឬស្សីបៃតង ១ ៣៧១ ហ.ត
ដីគ្មានគំរបព្រៃ ៣ ៩៥០ ហ.ត
ផ្ទៃដីសរុប ១០១ ៣៤៨ ហ.ត
N
W
E
S
5 2.5 0 5 Km
13°15N
13°20N
13°25N
13°30N
13°35N
107°20'E
107°25'E
107°30'E
107°35'E
750000
755000
760000
765000
770000
775000
780000
785000
1470000
1475000
1480000
1485000
1490000
1495000
1500000
1505000
757106 1468587
753702 1472840
767470 1475211
778346 1469506
773602 1508998
776848 1504546
75799 1507000